គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 883 750
E-mail: comfrel@online.com.kh Website: http://www.comfrel.org

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

1. លោក **ធន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

2. លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធាន គណៈកម្មាធិការ
នាយក និងជានាយក CDP

3. លោក **យឹម ប៉ូ**
Mr. YIM Po អគ្គលេខាធិការ និងជា
នាយក CCPCR

4. **អ្នកស្រី ស៊ុន ចាន់សែន**
Mrs. SUN Chansen សមាជិកា និង
ជាប្រធាន KYA

5. លោក **យ៉ង់ គិមអេង**
Mr. YONG Kim Eng សមាជិក និងជា
នាយក PDP-Center

6. លោក **មុំ សារិន**
Mr. MOM Sarin សមាជិក និងជា
នាយក HRCDO

7. **អ្នកស្រី ទីវ សារាយេត**
Ms. TIV Sarayet សមាជិកា និងជា
សហនាយិកា WMC

8. **កញ្ញា សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany សមាជិកា
និងជា នាយិកា CWCC

9. លោក **គីម សុវណ្ណ**
Mr. KIM Sovann សមាជិក និងជា
នាយក VIGILANCE

10. នាយក LAC (NA)

11. នាយក KKKHRO (NA)

12. **អ្នកស្រី ពឹង យក់ហៀប**
Ms. PEUNG Yok Hiep សមាជិកា ជា
ឥស្សរជន Dignitary

13. លោក **សឺន សែត**
Mr. SEN Set សមាជិក ជា
ឥស្សរជន Dignitary

**ខុមហ្វ្រែល អ្នកឃ្លាំមើល/អត្ថបទលេខ ៨៧**

ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# របាយការណ៍វេទិកាស្តីពីការបោះឆ្នោត និងប្រជាធិបតេយ្យ ក្នុងខេត្តបន្ទាយមានជ័យ

អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីរាជការនៃមន្ទីរជុំវិញខេត្ត គណៈកម្មការរៀបចំការបោះឆ្នោត ខេត្ត ឃុំ/សង្កាត់ តំណាងគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ នៃខេត្តបន្ទាយមានជ័យ ប្រមាណ ៩៧ នាក់ ក្នុងនោះមាន ស្ត្រី ចំនួន ២៥ នាក់ បានចូលរួមនៅក្នុងវេទិកាស្តីពី "**ការបោះឆ្នោត និង ប្រជាធិបតេយ្យ**" ដែលបានរៀបចំឡើងដោយ គណៈកម្មាធិការ **ខុមហ្វ្រែល** សហការណ៍ជាមួយ អង្គការ សមាគមមិនមែនរដ្ឋាភិបាល ក្នុងខេត្តបន្ទាយមានជ័យ ដូចជា សមាគមសិទ្ធិមនុស្ស **អាដហុក** (ADHOC) **សមាគមយុវជនខ្មែរ** (KYA) **អង្គការលីកាដូ** (LICADHO) **អង្គការអភិវឌ្ឍន៍សុខភាពសត្វជនបទ** (RADHO) និង **មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព** (PDP) ក្រោមការគាំទ្រថវិកាដោយ អង្គការ **UNDP** នៅសណ្ឋាគារ នាគមាស ក្នុងក្រុងសេរីសោភ័ណ្ឌ ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១០ កន្លងទៅនេះ។

គោលបំណងរបស់វេទិកា គឺផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធបានលើកឡើង និងពិភាក្សាគ្នាពីបញ្ហាដែលទាក់ទងទៅនឹងដំណើរការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជាហើយ ស្វែងរកនូវអនុសាសន៍ ឬយុទ្ធសាស្ត្រ និងរកការគាំទ្រ លើអនុសាសន៍ទាំងនោះ។

ក្នុងឱកាសនោះក៏មានវត្តមានជាវាគ្មិន រួមមាន ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី និងជា អ្នកតំណាងរាស្ត្រ គណបក្ស ហ្វ៊ុនស៊ិនប៉ិច មណ្ឌលខេត្តបន្ទាយមានជ័យ ឯកឧត្តម **យន្ត ថារ៉ូ** អ្នកតំណាងរាស្ត្រ គណបក្ស សម រង្ស៊ី មណ្ឌលខេត្តបន្ទាយមានជ័យ ឯកឧត្តម **ជង់ ប្រុសឺដ្ឋ** សមាជិកក្រុមប្រឹក្សា ខេត្តបន្ទាយមានជ័យ មកពីគណបក្សប្រជាជនកម្ពុជា លោក **សុក សំអឿន** អនុប្រធានគណកម្មាធិការនាយក គណកម្មាធិការ ខុមហ្វ្រែល និងជានាយក អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងលោក **យង់ គិមអេង** សមាជិកគណកម្មាធិការនាយក នៃគណកម្មាធិការ ខុមហ្វ្រែល និងជាប្រធាន មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព។

ក្នុងវេទិកានេះ សិក្ខាកាមបានរកឃើញអនុសាសន៍ដើម្បីកែលំអរបញ្ហាជាអត្ថិភាពប្រាំរួមមាន : បញ្ហាហិរញ្ញវត្ថុគណបក្សនយោបាយពេលឃោសនាបោះឆ្នោត ការរៀបចំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត សេរីភាពបញ្ចេញមតិ និងសេរីភាពប្រមូលផ្តុំ។ មានការខ្វែងយោបល់គ្នាលើអនុសាសន៍មួយក្នុងចំណោមអនុសាសន៍ទាំងអស់ដែលថា តើការចេញទំរង់ ១០១៨ ត្រូវបន្ត ឬអត់?

ឯកឧត្តម **ញឹក ប៊ុនឆៃ** បានបង្ហាញពីការព្រួយបារម្ភអំពីអនុសាសន៍ដែលថារក្សាការចេញទំរង់ ១០១៨ "...បើចង់ទុក ទំរង់ ១០១៨ ត្រូវតែមានការកែលំអរការគ្រប់គ្រង តើអ្នកណាជាអ្នកត្រួតពិនិត្យ...។"

ដោយឡែកឯកឧត្តម **យន្ត ថារ៉ូ** បានលើកឡើងថា "មិនគាំទ្រឱ្យប្រើប្រាស់ទំរង់ ១០១៨ ទៀតទេ..."។

ឯកឧត្តម **ជំ ប្រសិទ្ធ** ក៏បានលើកឡើងដែរថា " ខ្ញុំគិតថាជាការត្រឹមត្រូវចំពោះការកំណត់ថវិការសំរាប់បេក្ខជន ប្រើប្រាស់ពេលឃោសនាបោះឆ្នោត..."។

វាគ្មិនទាំងអស់រួមទាំងសិក្ខាកាមស្ទើរទាំងអស់ បានបង្ហាញការគាំទ្រចំពោះអនុសាសន៍មួយដ៏សំខាន់នោះ គឺ សមាសភាពមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត ជាពិសេសគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត ( PEC ) និងគណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ ( CEC ) ត្រូវមានសមាសភាពចំរុះគណបក្សនយោបាយ ពិសេសគណបក្សនយោបាយមានអាសនៈក្នុងសភា។

លោក **គល់ បញ្ញា** អ្នកសំរបសំរួលវេទិកា និងជានាយកប្រតិបត្តិរបស់ ខុមហ្វ្រែល សន្យាថានឹងរៀបចំ អនុសាសន៍ឱ្យ បានរៀបរយ ហើយនឹងបន្តបញ្ជូនអនុសាសន៍ទាំងនេះទៅស្ថាប័នពាក់ព័ន្ធទាំងអស់។ ខាងក្រោមនេះ គឺជាអនុសាសន៍ដែលសិក្ខាកាមពី **៦០%** ទៅ **៩០%** បានគាំទ្រ។

<table>
<tr><th colspan="4">អនុសាសន៍របស់ម្ចាស់ឆ្នោតនៅខេត្តបន្ទាយមានជ័យ ចូលរួមវេទិកាស្តីពី ប្រជាធិបតេយ្យ និង ការបោះឆ្នោត</th></tr>
<tr><th>ល.រ</th><th>អនុសាសន៍</th><th>ស្ថាប័នទទួលខុសត្រូវ</th><th>ភាគរយសំឡេង</th></tr>
<tr><td>១</td><td colspan="3">ហិរញ្ញវត្ថុគណបក្ស នយោបាយពេលឃោសនាបោះឆ្នោត</td></tr>
<tr><td colspan="2">ត្រូវបែងចែកថវិកាជូនគណបក្សទាំងអស់ឱ្យបានស្មើៗគ្នាទៅតាមលទ្ធភាពដែលអាចធ្វើបាន។ បេក្ខជនដែលឈរឈ្មោះជាតំណាងរាស្ត្រ មិនចំណាយថវិកាលើសពី ៣ ម៉ឺន ដុល្លា។ បេក្ខជនដែលឈរឈ្មោះជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់មិនត្រូវចំណាយ លើសពី ៥ ពាន់ ដុល្លា។</td><td>រដ្ឋសភា<br>និងរដ្ឋាភិបាល</td><td rowspan="4">គាំទ្រ : ៧៨%<br>មិនគាំទ្រ: ៨%<br>អនុបវាទ:១៤%</td></tr>
<tr><td colspan="2">ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុគ្រប់គណបក្ស (ចំណូល និងចំណាយ) ទាំងពេលឃោសនាបោះឆ្នោត ហើយ គ.ជ.ប ត្រូវតែផ្សព្វផ្សាយរបាយ ការណ៍នេះ មុនពេលបោះឆ្នោតម្តងទៀត។<br>គ.ជ.ប ជាអ្នកមានអំណាចដាក់ទណ្ឌកម្ម ចំពោះគណបក្សនយោបាយណាដែលក្លែងបន្លំរបាយការណ៍ចំណូលចំណាយ។</td><td>គ.ជ.ប</td></tr>
<tr><td colspan="2">អង្គការសង្គមស៊ីវិលជួយតាមដានត្រួតពិនិត្យ និងតាមដានចំណូល ចំណាយគ្រប់គណបក្សនយោបាយ និងផ្សព្វផ្សាយតាមប្រព័ន្ធឃោសនានានាឱ្យ ដល់ប្រជាពលរដ្ឋ។</td><td>អង្គការសង្គមស៊ីវិល</td></tr>
<tr><td colspan="2">ត្រូវតែផ្សព្វផ្សាយនូវថវិកា ដែលគ.ជ.បកំណត់ និងឱ្យ ដល់សមាជិកនៃគណបក្សរបស់ខ្លួន។</td><td>គណបក្សនយោបាយ</td></tr>
</table>

| | | |
|---|---|---|
| ២ **<u>បញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត</u>** | | |
| ការធ្វើប្រតិភូកម្មនៃ គ.ជ.ប ឱ្យទៅអាជ្ញាធរមូលដ្ឋានដូចជាការចុះឈ្មោះបោះឆ្នោត ដោយឱ្យមានសំរេចជាវិធានការច្បាប់មួយ ។ ការចុះឈ្មោះបោះ ឆ្នោតគួរតែមានរយៈពេលអចិន្ត្រៃយ៍ ។ | រដ្ឋសភា<br>និងរដ្ឋាភិបាល | គាំទ្រ : ៦០%<br>មិនគាំទ្រ: ៣២%<br>អនុបវាទ: ៧% |
| រក្សាទុកទំរង់ ១០១៨ ប៉ុន្តែកែលំអរនីតិវិធីនៃការចេញទំរង់ ១០១៨ ប្រកបដោយសមធម៌ ពុំមានលំអៀង ( មានការដាក់រូបថតឱ្យបានច្បាស់លាស់ លេខរៀង ពេលវេលា) ។ | គ.ជ.ប | |
| មេភូមិ មេប៉ុស្តិ៍ សហការគ្នារកឱ្យឃើញអ្នកដែលស្លាប់ និងអ្នកដែលធ្វើចំណាកស្រុក ព្រមទាំងភ្ជាប់មកជាមួយនូវសាក្សី និងឯកសារភស្តុតាងផង ។ យកឈ្មោះដែលត្រូវលុបចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតយកទៅបញ្ចូលទៅ ក្នុងទំរង់ ១០២៥ ដើម្បី ឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើការសំរេចលុប ឈ្មោះ ។ យកបញ្ជីឈ្មោះអ្នកបោះឆ្នោតបិទប្រកាសត្រួតពិនិត្យឱ្យបានត្រឹមត្រូវទៅតាមភូមិនីមួយៗតាមរយៈមេភូមិនៅតាមតំបន់នោះ ។ | អាជ្ញាធរមូលដ្ឋាន<br>និងអ្នកអនុវត្តច្បាប់ | |
| ៣ **គណៈកម្មាធិការជាតិរៀបចំការបោះ ឆ្នោត <u>គ.ជ.ប</u>** | | |
| គួរតែអនុម័តថវិកាស្វ័យយ័តចំពោះ គ.ជ.ប ។ រដ្ឋសភាគួរវិសោធនកម្មមាត្រាខ្លះនៅក្នុងច្បាប់ រដ្ឋធម្មនុញ្ញដើម្បីចែងបង្កើតស្ថាប័ន គ.ជ.ប ជាស្ថាប័ន កើតឡើងដោយរដ្ឋធម្មនុញ្ញ ។ | រដ្ឋសភា<br>និងរដ្ឋាភិបាល | |
| ត្រូវជ្រើសរើសសមាសភាពចំរុះពីគណបក្សនយោបាយសំរាប់ គណៈកម្មការរៀបចំការបោះឆ្នោត ខេត្ត (PEC) និង គណៈកម្មការរៀបចំការបោះឆ្នោត ឃុំសង្កាត់ (CEC) ដែលស្របតាមលក្ខណៈវិនិច្ឆ័យរបស់ គ.ជ.ប បច្ចុប្បន្ន ។ ប្រាក់ឧបត្ថម្ភដល់មន្ត្រីការិយាល័យបោះឆ្នោត ( PSO ) គួរ តែ ២០ ទៅ ៤០ម៉ឺន ។<br>-ត្រូវបានបង្កើតដោយតុលាការ ឬអង្គជំនុំជំរះមួយ ដែលចេញពី គ.ជ.ប ដើម្បីដោះស្រាយវិវាទ បោះឆ្នោត ។<br>-ត្រូវរកទីស្នាក់ការឯករាជ្យ ដាច់ដោយឡែកពីក្រសួងមហាផ្ទៃ ។ ត្រូវមានក្រុមមន្ត្រីបម្រើការងារជាអចិន្ត្រៃយ៍នៅ គណៈកម្មការរៀបចំការបោះ ឆ្នោត ឃុំសង្កាត់ (CEC) ។ | គ. ជ. ប | គាំទ្រ : ៩៤%<br>មិនគាំទ្រ:៧%<br>អនុបវាទ: 0% |
| ៤ **សេរីភាពនៃការបញ្ចេញមតិ និងប្រមូលផ្តុំ** | | |
| ១-សុំឱ្យមានការគំណត់ឱ្យបានច្បាស់អំពី និយមន័យនៃពាក្យ  អ្វីទៅ:<br>-ការបញ្ចេញមតិ<br>-ការផ្សព្វផ្សាយព័ត៌មានមិនពិត ញុះញង់ ជេរប្រមាថ<br>-បរិហារកេរ្តិ៍ ដោយប្រើពាក្យសំរាយងាយយល់ ។<br>-កំណត់ឱ្យបានច្បាស់អំពីធាតុផ្សំនៃ បទល្មើស ។<br>២-សុំឱ្យរដ្ឋាភិបាលមានការផ្សព្វផ្សាយ អំពីមតិជំទាស់/រិះគន់ និងសកម្មភាពរបស់គណបក្សមិនកាន់អំណាចក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ជាទៀងទាត់ ( មានកម្មវិធីទៀតទាត់)<br>៣-សុំឱ្យរដ្ឋាភិបាលបង្កើតកម្មវិធីផ្សព្វផ្សាយអំពីការបញ្ចេញមតិរបស់ប្រជាពលរដ្ឋក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ។ | រដ្ឋសភា<br>និងរដ្ឋាភិបាល | គាំទ្រ : ៦០%<br>មិនគាំទ្រ: ៣២% |

| | | |
|---|---|---|
| ៤-សុំឱ្យរដ្ឋាភិបាលពង្រឹងការអនុវត្តច្បាប់របស់អាជ្ញាធរមូលដ្ឋាន។ សុំឱ្យកែទំលាប់មកអនុវត្តទៅតាមច្បាប់វិញ (ត្រឹមការជូនដំណឹងមិនចាំបាច់ សុំច្បាប់)<br>៥-សុំមិនបាច់កំណត់ចំនួនអ្នកចូលរួមការប្រមូលផ្តុំ។ សូមឱ្យមានការដាក់ទណ្ឌកម្ម ចំពោះអ្នកដែលគំរាមកំហែងទៅអ្នកដែលផ្តល់ទីកន្លែង ដើម្បី ធ្វើការប្រមូលផ្តុំគ្នា។ | | អនុបវាទ: ៧% |
| សុំឱ្យកែទំលាប់មកអនុវត្តទៅតាម ច្បាប់វិញ (ត្រឹមការជូនដំណឹង មិនចាំបាច់សុំច្បាប់ ក្នុងការធ្វើបាតុកម្ម) | អាជ្ញាធរមូលដ្ឋាន និងអ្នកអនុវត្តច្បាប | |

សំរាប់ព័តិមានលំអិតសូមទាក់ទង :

លោក **ចំនួ ដារិទ្ធ** (អ្នកសម្របសម្រួលព័តិមាន គណ:កម្មាធិការ ខុមហ្វ្រែល)

ទូរស័ព្ទលេខ : **០១២ ៨៤៦ ២១១**